# គំនិតអនោតស្រះនៅព្រះវិហារវត្តក្តីដើម

**អនោតស្រះ** ជាពាក្យក្នុងភាសាបាលីដែលមានសំណេរដើមថា "**អនោតត្ត**" ហើយត្រូវនឹងភាសាសំស្ក្រឹតថា "**អនវតបត្ត**" ដែលប្រែជាខ្មែរថា "**មិនត្រូវកម្តៅ**"។[១] នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧(គ.ស.១១៨១-១២១៨) ទ្រង់និយមយកគំនិតដែលមាននៅក្នុងគម្ពីរព្រះពុទ្ធសាសនាមហាយានមកប្រណិប័តន៍នៅលើទីស្ថានមនុស្សណាស់។ ឧទាហរណ៍ ប្រាសាទនាគព័ន្ធដែលសាងនៅកណ្តាលស្រះ និងស្ថិតនៅចំចំណុចកណ្តាលបារាយណ៍ជយតដាក (សព្វថ្ងៃអ្នកស្រុកហៅ "**រាលរាជដាក**" អ្នកប្រាជ្ញធំៗជាច្រើនយល់ថា គឺជានិម្មិតរូបតំណាងឱ្យស្រះស្ងួតនៅភ្នំហិមល័យឈ្មោះថា "**អនវតបត្ត**"។[២] នៅទីនោះ មានស្រះទឹកចំនួនប្រាំ ហើយក្នុងចំណោមក្រុមស្រះទាំងប្រាំមានស្រះធំមួយនៅចំកណ្តាល និងស្រះតូចជាងនេះ តែមានទំហំប៉ុនៗគ្នាបួនទៀតអមនៅតាមទិសទាំងបួនហាក់ដូចជាបរិវារនៃស្រះកណ្តាលនោះ។ នៅចំកណ្តាលស្រះធំ គឺជាសំណង់ប្រាសាទនាគព័ន្ធដែលគេឆ្លាក់រូបនាគពីររុំព័ន្ធគ្នា រីនៅស្រះតូចៗវិញមានបន្ទប់បង្ហូរទឹកដែលមានទនាំទឹកពីស្រះធំហើយចុងទនីមួយៗមានរូបក្បាលសត្វឬមនុស្ស (ខាងកើតរូបក្បាលមនុស្ស, ខាងត្បូងមាត់សិង្ហ, ខាងលិចមាត់សេះ, និងខាងជើងមាត់ដំរី)។ គំនិតនេះហើយដែលអ្នកប្រាជ្ញធំជាច្រើនយល់ថា វាជានិម្មិតរូបតំណាងឱ្យស្រះស្ងួតនៅភ្នំហិមល័យឈ្មោះថា "**អនវតបត្ត**" ហើយលោក ស៊ីយ៉ុន សុភារិទ្ធ យល់ថារូបក្បាលមនុស្សដែលនៅខាងកើតជានិម្មិតរូបតំណាងឱ្យព្រះនាងគង្គា ពោល គឺជាទេពតំណាងឱ្យទឹក។[៣] គំនិតនេះ បានបន្តមកដល់សម័យកណ្តាល ដ្បិតយើងឃើញនៅសម័យនោះគេមានគម្ពីរត្រៃភូមិដែលមាននិយាយអំពីអនោតស្រះដូចគ្នា។ អ្វីគួរកត់សម្គាល់នោះគឺ នៅលើខឿនព្រះវិហារវត្តក្តីដើមដែលទើបនឹងសាងប្រមាណ ១០០ឆ្នាំជាងនេះ ក៏មានទបង្ហូរទឹកជារូបក្បាលសត្វដែរ។ តើទបង្ហូរទឹកនៅលើខឿនព្រះវិហារវត្តក្តីដើមគឺជានិម្មិតរូបតំណាងឱ្យអនោតស្រះដូចប្រាសាទនាគព័ន្ធដែរឬទេ?

វត្តក្តីដើម មានទីតាំងស្ថិតនៅក្បែរស្ទឹងស្ទោង ត្រង់ភូមិកំពង់ចិន ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ៥១ គីឡូម៉ែត្រ ភាគខាងលិចទីរួមខេត្តកំពង់ធំ ហើយជាទីតាំងដែលធ្លាប់មានប្រាសាទចាស់សាងអំពីឥដ្ឋកាលពីស.វ.ទី១១ ប៉ុន្តែក្រោយមកទៀត

---

១.ស៊ីយ៉ុន សុភារិទ្ធ ២០០៩: ៨។

២ Sadakata 1997: 31-39.

៣ ស៊ីយ៉ុន សុភារិទ្ធ ២០០៩: ៥។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

គេបានសាងព្រះវិហារនៅលើគ្រឹះប្រាសាទចាស់ធ្វើឱ្យបាត់រូបរាងទៅហើយ។ នៅបរិវេណវត្តក្ដីដើម មានព្រះវិហារបុរាណមួយដែលសាងឡើងនៅគ.ស.១៩៣០ (រូបលេខ១-២) ហើយសង់នៅលើខឿនចាស់មួយដែលមានអាយុកាលប្រមាណ ១០០ ឆ្នាំជាងមកហើយ (រូបលេខ៣-៤)។ ខឿនព្រះវិហារដ៏ចំណាស់នេះ សាងឡើងអំពីឥដ្ឋបូកកំបោរបាយអ ដែលស្ថាបត្យករយកលំនាំតាមរចនាបថខ្មែរខ្លះ និងរចនាបថបែបសំណង់បារាំងខ្លះ។ នៅលើបង្កាន់ដៃខឿនព្រះវិហារនេះ គេលម្អជាក្បាច់រង្វង់រាងពងក្រពើតម្រៀបគ្នាគ្រប់ទិសទាំងបួនមានចំនួនសរុប ៤០១រង្វង់។ ចំពោះ ទបង្ហូរទឹកវិញ គេរំលេចដោយរូបក្បាលសត្វផ្សេងៗគ្រប់ទិសទាំងបួន ហើយក្នុងមួយទិសគេដាក់ទបង្ហូរទឹកចំនួនពីរនៅអមសងខាងក្លោងទ្វារចូលចម្ងាយពីទ្វារប្រមាណ៣ម៉ែត្រ ប៉ុន្ដែជារូបតែមួយដូច្នេះសរុបមានចំនួន ៨។ គួរឱ្យសោកស្ដាយនៅខាងជើង ទបង្ហូរទឹកមួយបានបាត់បង់ទៅហើយ។ ទបង្ហូរទឹកនីមួយៗមានទំហំវិជ្ជមាត្រនិងកម្ពស់ប្រហាក់ប្រហែលគ្នា ពោល គឺកម្ពស់ចន្លោះពី៣០ដល់៤០ស.ម.។ នៅខាងកើតគេដាក់ទបង្ហូរទឹកជារូបក្បាលជ្រូកចំនួន២ (រូបលេខ៥-៦) ខាងត្បូងជារូបក្បាលគោចំនួន២ (រូបលេខ៧-៨) ខាងលិចជារូបក្បាលរាហូចំនួន២ (រូបលេខ៩-១០) និងខាងជើងជារូបក្បាលដំរីចំនួន២ តែបាត់បង់១សល់តែ១ (រូបលេខ១១)។

មានគម្ពីរជាច្រើនបាននិទានអំពីរឿងអនោតស្រះ ដូចជាគម្ពីរទីឃាគមសូត្រ គម្ពីរអភិធម៌កោស គម្ពីរត្រៃភូមិ ។ល។ នៅក្នុងគម្ពីរទីឃាគមសូត្រ[៤] បានរៀបរាប់ថា៖ "នៅលើកំពូលភ្នំហិមល័យមានស្រះទឹកមួយឈ្មោះថា "អនវតប្ដ"។ ស្រះនេះមានទឹកត្រជាក់ថ្លាយង់ ហើយជាទឹកបរិសុទ្ធឥតខ្ចោះ។ ជុំវិញស្រះមានជញ្ជាំងកំពែង៧ជាន់ធ្វើអំពីវត្ថុមានតម្លៃ៧ជាន់ ដែលមានពណ៌ផ្សេងៗគ្នា។ បាតស្រះក្រាលដោយគ្រប់ខ្សាច់មាស។ នៅទៀបមាត់ស្រះមានឧទ្យាននិងទីសម្រាប់ងូតទឹកប្រកបដោយដើមឈើគ្រប់ប្រភេទ មានផ្លែផ្កាក្រអូបឈ្ងុយឈ្ងប់ មានបក្សីគ្រប់បែបយ៉ាងយំប្រចឹកគ្នាលេងយ៉ាងសប្បាយ។ តាមជ្រុងនីមួយៗនៃអនវតប្ដមានជណ្ដើរចុះទៅក្នុងស្រះ។ ជណ្ដើរប្រាក់មានបង្កាន់ដៃមាស រីឯជណ្ដើរមាសមានបង្កាន់ដៃប្រាក់។ បង្កាន់ដៃនៅជុំវិញស្រះនេះមានផ្កាចម្រុះពណ៌ក្រហម ខៀវ លឿង និងស។ នៅខាងកើតស្រះមានទន្លេ គង្គា ដែលហូរចេញតាមមាត់គោធ្លាក់ទៅសមុទ្រខាងកើត។ ខាងត្បូងមានទន្លេ សិន្ធុ ហូរតាមមាត់សិង្ហធ្លាក់ទៅសមុទ្រខាងត្បូង។ ខាងលិចមានទន្លេ វក្សុ ហូរតាមមាត់សេះធ្លាក់ទៅសមុទ្រខាងលិច។ ខាងជើងមានទន្លេ សីតា ហូរ

---

[៤] Sadakata 1997: 31-39.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*តាមមាត់ជំរឿធ្លាក់ទៅសមុទ្រខាងជើងៗ នៅកណ្ដាល អនវតប្ដ មានព្រះរាជដំណាក់ដែលស្ដេចនាគព្រះនាម "អនវតប្ដ" គង់នៅប្រចាំ"ៗ*

នៅក្នុងគម្ពីរទីឃាគមសូត្រខាងលើនេះ បង្ហាញឱ្យឃើញថា ខាងកើតត្រូវនឹងក្បាលគោ ខាងត្បូងក្បាលសិង្ហ ខាងលិចក្បាលសេះ ខាងជើងក្បាលដំរីៗ ចំណែក គម្ពីរមួយទៀតឈ្មោះថា អភិធម៌កោស សត្វតំណាងឱ្យទិសមានភាពខុសគ្នាតិចតួចពីគម្ពីរទីឃាគមសូត្រ ពោល គឺខាងកើតក្បាលដំរី ខាងត្បូងក្បាលគោ ខាងលិចក្បាលសេះ និងខាងជើងក្បាលសិង្ហៗ គម្ពីរទាំងពីរនេះ បើសិនយើងយកមកធៀបជាមួយគម្ពីរត្រៃភូមិរបស់ខ្មែរនៅដើមសម័យកណ្ដាលក៏ពុំត្រូវគ្នាទាំងស្រុងដែរ ពោល គឺមានការឃ្លៀងឃ្លាតខុសគ្នាតិចតួច ដ្បិតនៅក្នុងគម្ពីរត្រៃភូមិ គេនិទានថា ខាងកើតក្បាលគោ ខាងត្បូងក្បាលសេះ ខាងលិចក្បាលដំរី និងខាងត្បូងក្បាលសិង្ហៗ

ចំណុចគួរកត់សម្គាល់ គឺគម្ពីរទាំងបីដែលរៀបរាប់នេះ ក៏មានការឃ្លៀងឃ្លាតគ្នាខ្លះជាមួយទបង្ហូរទឹកនៅប្រាសាទនាគព័ន្ធដែរៗ ដ្បិតនៅប្រាសាទនាគព័ន្ធ ទបង្ហូរទឹកនៅខាងកើតមានក្បាលមនុស្ស ខាងត្បូងក្បាលសិង្ហ ខាងលិចក្បាលសេះ និងខាងជើងក្បាលដំរីៗ ទិសនៃសត្វនៅក្នុងគម្ពីរទាំងបីខាងលើផង និងគំនិតដែលមាននៅប្រាសាទនាគព័ន្ធផង ពុំត្រូវគ្នាទាំងស្រុងជាមួយទបង្ហូរទឹកនៅខឿនព្រះវិហារវត្តក្ដីដើមឡើយៗ ដ្បិតនៅវត្តក្ដីដើមយើងឃើញនៅខាងកើតជាទបង្ហូរទឹករូបក្បាលជ្រូក ខាងត្បូងក្បាលគោ ខាងលិចក្បាលរាហូ និងខាងជើងក្បាលដំរីៗ ពោល គឺមានន័យថា ទបង្ហូរទឹករូបសត្វទាំងបួននេះពុំមានស្របជាមួយគម្ពីរណាមួយដែលលើកឡើងខាងលើនោះឡើយៗ ប៉ុន្តែក៏មានទិសខ្លះដូចគ្នាដែរ ឧទាហរណ៍ ទិសខាងជើងជារូបក្បាលដំរីដូចគ្នាជាមួយគម្ពីរទីឃាគមសូត្រ រីឯខាងត្បូងក្បាលគោមានភាពស្របគ្នាជាមួយគម្ពីរអភិធម៌កោសៗ ប្រការនេះយើងមិនដឹងជាក់ច្បាស់ថាហេតុអ្វីបានជាដូច្នេះឡើយៗ ប៉ុន្តែ យើងគិតថាទបង្ហូរទឹកនេះក៏មិនខុសពីទបង្ហូរទឹកនៅប្រាសាទនាគព័ន្ធដែរ ពោល គឺមានការឃ្លៀងឃ្លាតគ្នាខ្លះពីគម្ពីរ តែគំនិតជារួមមួយគឺទបង្ហូរទឹកនេះតំណាងឱ្យស្រះសួគ៌នៅភ្នំហិមល័យដែលជាទីស្ថានរបស់ទេព ក្នុងគំនិតអនោតស្រះ បើទោះបីជានៅជុំវិញព្រះវិហារវត្តក្ដីដើមពុំមានស្រះបួនអមជុំវិញដូចនៅប្រាសាទនាគព័ន្ធក៏ដោយៗ ការប្រើប្រាស់គំនិតដូច្នេះមិនខុសពីសម័យបុរាណកាលឡើយ ដែលទំនងគេយល់ថា ព្រះវិហារគឺជាសំណង់នៅស្ថានសួគ៌ដែលប្រតិស្ឋាននៅស្ថានមនុស្ស ម្ល៉ោះហើយត្រូវច្នៃប្រឌិតនិងសាងបែបណាឱ្យមើលទៅមានលក្ខណៈជាសំណង់សួគ៌ដ៏ពិសិដ្ឋៗ គំនិតគួរកត់សម្គាល់មួយទៀតនោះគឺ នៅទិសខាងលិចគេដាក់ទបង្ហូរទឹកមានរូបក្បាលរាហូ ដែលជាសត្វទេវកថាមួយប្រភេទនៅក្នុង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ព្រហ្មញ្ញសាសនាដែលធ្លាប់បានលេបទឹកអម្រឹតតាមរយៈទេវកថាកូរសមុទ្រទឹកដោះ[៥] និងខ្មែរតែងយល់ថារាហូគឺជានិម្មិតរូបនៃសេចក្ដីស្លាប់ និងការកើតឡើងវិញ ដូចយើងធ្លាប់ឃើញគេដាក់រូបក្បាលរាហូនៅតាមមជ្ឈូសខ្មែរ ដ្បិតគេជឿថាទិសខាងលិច គឺជាទិសតំណាងឱ្យសេចក្ដីស្លាប់ឬទិសខ្មោចៗ[៦]

ជារួមមក ទោះបីជាទបង្ហូរទឹកនៅលើខឿនព្រះវិហារវត្តក្ដីដើមមានឆ្លាក់រូបក្បាលសត្វពុំស្របទាំងស្រុងជាមួយទិសនៃសត្វនៅក្នុងគម្ពីរដែលរៀបរាប់ខាងលើក៏ដោយ ក៏ទំនងជាអ្នកសាងធ្វើឡើងក្នុងគំនិតអនោតត្តស្រះដូចនៅប្រាសាទនាគព័ន្ធដែរ ពោល គឺជានិម្មិតរូបតំណាងឱ្យស្រះសួគ៌នៅភ្នំហិមល័យ និងអាចជាគំនិតយល់ថាសំណង់ព្រះវិហារគឺជាសំណង់នៅស្ថានសួគ៌ដែលគេប្រតិស្ឋាននៅស្ថានមនុស្សៗ ម្ល៉ោះហើយ ទឹកដែលចេញពីមាត់សត្វទាំងបួនតាមទិសនីមួយៗដែលគេឆ្លាក់ដាក់នោះ គឺជាទឹកពិសិដ្ឋនិងជាភោគផលសម្រាប់ស្ថានមនុស្សៗ

## បញ្ជីឯកសារយោង


**ស៊ីយ៉ុន សុភារិទ្ធ**

២០០៩, "ប្រាសាទនាគព័ន្ធ៖ "តីថ៌" ជម្រះមន្ទិលបាបកម្ម", *ឧទ័យ*, លេខ១០, ភ្នំពេញ

**Ang, Chouléan**

2004, "La mort-renaissance en abstraction iconograhphique", *UDAYA*, *Numéro 5*, Phnom Penh

**Sadakata, Akira**

1997, *Buddhist Cosmology, Philosophy and Origins, Tokyo*

**Thomas, Paul**

1999, *"Epics, myths and legends of India"*, Treasure House of Books, Bommbay


[៥] Thomas 1999: 93.

[៦] Ang Choulean 2004: 85-96.



ឱ្យ១៖ ព្រះវិហារវត្តក្តីដើម (មើលពីទិសអាគ្នេយ៍)



ឱ្យ២៖ ព្រះវិហារវត្តក្តីដើម (មើលពីទិសខាងជើង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ខឿនព្រះវិហារវត្តក្តីដើម មើលពីទិសឦសាន



រូបលេខ៤៖ ខឿនព្រះវិហារវត្តក្តីដើម មើលពីទិសខាងកើត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥-៦៖ ទបផ្លូវទឹករូបក្បាលជ្រូកនៅទិសខាងកើត (ផ្នែកខាងជើង និងត្បូង)



រូបលេខ៧-៨៖ ទបផ្លូវទឹករូបក្បាលគោនៅទិសខាងត្បូង (ផ្នែកខាងកើត និងលិច)



រូបលេខ៩-១០៖ ទបផ្លូវទឹករូបក្បាលរាហូនៅទិសខាងលិច (ផ្នែកខាងត្បូង និងជើង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ ទបង្ហូរទឹករូបក្បាលដំរីនៅទិសខាងជើង (ផ្នែកខាងលិច)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION